# សេចក្តីថ្លែងការណ៍រួម

នេះគឺជាសេចក្តីថ្លែងការណ៍រួម រវាង**គ្រឹះស្ថាន អិលអូអិលស៊ី** និង **ដើមបណ្តឹង** ពាក់ព័ន្ធនឹងការវិនិយោគដោយប្រយោលរបស់ IFC ជាមួយគ្រឹះស្ថាន អិលអូអិលស៊ី តាមរយៈទំនាក់ទំនងហិរញ្ញវត្ថុរបស់គ្រឹះស្ថានទាំងនេះជាមួយ MIFA (លេខគម្រោង IFC #31467)។ ពាក្យបណ្តឹងនេះត្រូវបានដាក់ឈ្មោះសម្គាល់ថា "Cambodia MIFA Debt Fund 18"។

ក្នុងអំឡុងពេលនៃដំណើរការវាយតម្លៃរបស់ CAO ដើមបណ្តឹង និងអតិថិជនបន្តរបស់ IFC គឺគ្រឹះស្ថាន អិលអូអិលស៊ី បានសម្តែងការចាប់អារម្មណ៍ ចូលរួមក្នុងដំណើរការដោះស្រាយវិវាទដែលសម្របសម្រួលដោយ CAO ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងពាក់ព័ន្ធនឹងគ្រឹះស្ថាន អិលអូអិលស៊ី ដោយប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួមសហការ។ ភាគីទាំងពីរបានឯកភាពលើវិធានជាមូលដ្ឋាន សម្រាប់ការសម្រុះសម្រួល នៅក្នុងខែតុលា ឆ្នាំ២០២៥។

ជាលទ្ធផលនៃការចូលរួមដោះស្រាយវិវាទដោយស្ម័គ្រចិត្តនេះ ភាគីទាំងពីរបានឈានដល់ និងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៥ និងបានឯកភាពឱ្យ CAO ធ្វើការតាមដានការអនុវត្តកិច្ចព្រមព្រៀងផ្សះផ្សានេះ សម្រាប់រយៈពេល ១៨ខែ រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៧ ជាមួយនឹងលទ្ធភាពអាចបន្តរយៈពេលតាមដាននេះបាន។

ប្រើប្រាស់តែសម្រាប់គោលបំណងផ្លូវការប៉ុណ្ណោះ